ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy.

N° ៣៩០ ឧរម.សអកប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០០៣

# ប្រកាស
## ស្តីពីការបង្កើតស្តង់ដារឧស្សាហកម្មកម្ពុជា CS 008-2003
## អំពីអំពូលភ្លុយអិរេសង់ទីប ការតំរូវសុវត្ថិភាព

*

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែ និងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផលទំនិញនិងសេវា
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីស្តង់ដារឧស្សាហកម្មកម្ពុជា
- បានឃើញសេចក្តីជូនដំណឹងស្តីពីការប្រកាសស្តង់ដារព្រាងអំពីផលិតផលអំពូលភ្លុយអិរេសង់ទីប លេខ១៤៧៥ ឧរថសឧក.សជណ ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ២០០២
- យោងកំណត់ហេតុអង្គប្រជុំរបស់គណៈកម្មការបច្ចេកទេសស្តង់ដារឧស្សាហកម្មលើក ទី ៥ ស្តីពីការប្រជុំពិនិត្យនិងពិភាក្សាលើសេចក្តីព្រាងស្តង់ដារឧស្សាហកម្មកម្ពុជា CS00X-2002 អំពីអំពូលភ្លុយអិរេសង់ទីប ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០២។
- យោងតាមស្ថានភាពជាក់ស្តែងនាពេលបច្ចុប្បន្ន ។

## សម្រេច

ប្រការ ១ : បង្កើតស្តង់ដារឧស្សាហកម្មកម្ពុជា CS 008-2003 អំពីអំពូលភ្លុយអិរេសង់ទីប ស្តង់ដារបញ្ជាក់សំរាប់កំណត់អំពីរូបរាងនិងទំហំ ការតំរូវ ការធ្វើស្លាកសញ្ញា និងការដាក់ម៉ាក ការយកគំរូជាលក្ខណៈ ការធ្វើតេស្ត និងលក្ខណៈវិនិច្ឆ័យសំរាប់ភាពអនុលោមនៃអំពូលភ្លុយអិរេសង់ទីប ដែលផលិតក្នុងស្រុក និងនាំចូលពីបរទេស សំរាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងឧបសម្ព័ន្ធភ្ជាប់ជាមួយ ។

ប្រការ ២ ៖ ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសិប្បកម្មដែលផលិត ឬនាំចូលផលិតផលអំពូលភ្លើងអគ្គិសនីសម្រាប់ធ្វើចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុលោមតាមស្តង់ដារនេះជាដាច់ខាត ហើយត្រូវប្រើសញ្ញាស្តង់ដារឧស្សាហកម្មកម្ពុជា បោះពុម្ព ឬបិទភ្ជាប់លើផលិតផលរបស់ខ្លួន បន្ទាប់ពីបានទទួលអាជ្ញាប័ណ្ណស្តង់ដារ ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ ៖ ប្រកាស ឬសេចក្តីសម្រេចទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៤ ៖ ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។ [illegible]

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ស៊ុយ_សែម

**ចំលងជូន ៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
(ដើម្បីជូនជ្រាប)
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងសុខាភិបាល
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងពត៌មាន
-ក្រសួងអប់រំយុវជន និងកីឡា
-ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន
-ក្រសួងយុត្តិធម៌
-សភាពាណិជ្ជកម្មកម្ពុជា
-គ្រប់សាលាខេត្ត- ក្រុង
-គ្រប់មន្ទីរឧស្សាហកម្មរ៉ែ និងថាមពលខេត្ត- ក្រុង
(ដើម្បីសហការអនុវត្ត)
-ឯកសារ-កាលប្បវត្តិ